ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

លេខ ២៧៧៣ អ/ភស

ភ្នំពេញ, ថ្ងៃទី ០៦ ខែ ៥ ឆ្នាំ ២០០៦

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

ជំរាបមក

លោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត-ក្រុង
អនុវត្តគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP)

កម្មវត្ថុ : ការអនុវត្តនីតិវិធីចុះបញ្ជីដី-ការផ្ទេរសិទ្ធិ និងការចុះបន្ទុកលើដី-ផ្ទះ ក្នុងតំបន់ដែលកំពុងធ្វើការវិនិច្ឆ័យ និង តំបន់ដែលបានធ្វើការវិនិច្ឆ័យរួចហើយ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបអស់លោក លោកស្រីជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ឱ្យបានជ្រាបថា : កន្លងមក ការស្នើសុំចុះបញ្ជីដីតាមនីតិវិធីដាច់ដោយដុំ ការផ្ទេរសិទ្ធិ និងការដាក់បន្ទុកលើដី-ផ្ទះ ក្នុងតំបន់វិនិច្ឆ័យ តែងជួបការលំបាក ដោយនៅខ្វះគោលការណ៍ណែនាំ និងនីតិវិធីអនុវត្តច្បាស់លាស់ ។ ដើម្បីដោះស្រាយករណីនេះ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ សូមធ្វើការណែនាំ ដូចតទៅ :

១-ការស្នើសុំចុះបញ្ជីដីតាមនីតិវិធីដាច់ដោយដុំ ក្នុងតំបន់ដែលបានប្រកាសតំបន់វិនិច្ឆ័យរួចហើយ ត្រូវបានអនុញ្ញាតឱ្យអនុវត្ត ដោយត្រូវគិតពីរយៈពេលដែលនឹងត្រូវចេញប័ណ្ណ ចៀសវាងការទទួលប័ណ្ណតាមនីតិវិធីដាច់ដោយដុំ និងការទទួលប័ណ្ណតាមនីតិវិធីមានលក្ខណៈជាប្រព័ន្ធ នៅពេលជាមួយគ្នា ឬការទទួលប័ណ្ណតាមនីតិវិធីដាច់ដោយដុំ ក្រោយពេលទទួលប័ណ្ណតាមនីតិវិធីមានលក្ខណៈជាប្រព័ន្ធ ។

២-ការផ្ទេរសិទ្ធិក្នុងប័ណ្ណដីចាស់ (ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ) អាចអនុញ្ញាតគ្រប់ពេលរហូតវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុត្រូវបានផ្តល់ជូនតាមនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ។ ក្រោយពេលចែកវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុថ្មី ប័ណ្ណដីចាស់នឹងត្រូវបានចាត់ទុកជាមោឃៈលែងមានសុពលភាពប្រើប្រាស់តាមផ្លូវច្បាប់ទៀតហើយ ។ រាល់ការលួចប្រើប្រាស់ដោយបំពាន នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

៣-នៅពេលអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ក្រុមការងារតែងតែកត់ចូលក្នុងទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី នូវពត៌មានជាក់ស្តែងដែលទទួលបានពេលចុះប្រតិបត្តិការ ដោយមិនគិតពីការផ្ទេរសិទ្ធិក្រៅច្បាប់ឡើយ ។ ករណីនេះ នាំមកនូវភាពស្មុគស្មាញដល់ការធ្វើនិយ័តកម្មឯកសារនៃការផ្ទេរសិទ្ធិតាមច្បាប់ និងការបង់ពន្ធប្រថាប់ត្រា ។ ក្នុងឯកសារគោលទាក់ទងនឹងសិទ្ធិលើក្បាលដីមានតែទំរង់បែបបទនៃការប្រមូលទិន្នន័យតែមួយគត់ដែលអាចយកមកធ្វើជាមូលដ្ឋានក្នុងការប្រថាប់ត្រាបង់ពន្ធបាន ។ ចំណុចដែលត្រូវបោះត្រា គឺផ្នែកខាងស្តាំដៃនៃចំណុច **៣ -សិទ្ធិលើអចលនវត្ថុ** ឬ នៅបន្ទាត់ខាងក្រោមចំពាក្យថា " **ទិញ** " តែម្តង ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង អនុវត្តតាមការណែនាំនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

អគ្គនាយក ,ℵ

លឹម វ៉ាន់

<u>ចម្លងជូន</u> :

- ក្រសួង ដ.ន.ស
- គ្រប់សាលាខេត្ត-ក្រុង អនុវត្តគំរោង LMAP

" <u>ដើម្បីជូនជ្រាប</u> "

- នាយកដ្ឋានអភិរក្ស សុរិយោដី
- ឯកសារ-កាលប្បវត្តិ